# ធនាគារពិភពលោកត្រៀមខ្លួនជាស្រេចជួយគាំទ្រកម្ពុជាក្នុងការធ្វើឱ្យប្រសើរឡើង នូវជីវភាពរស់នៅរបស់ប្រជាជនដែលត្រូវបានរុះរើលំនៅដ្ឋាន

**ទីក្រុងវ៉ាស៊ិនតោន -- ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ --** ប្រធានធនាគារពិភពលោកទទួលបន្ទុកតំបន់អាស៊ីអាគ្នេយ៍ បានមានប្រសាសន៍នៅថ្ងៃនេះថា ធនាគារពិភពលោកត្រៀមខ្លួនជាស្រេច ដើម្បីជួយប្រទេសកម្ពុជា ក្នុងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលត្រូវបានរុះរើលំនៅដ្ឋាន ឬកំពុងប្រឈមនឹងការរុះរើលំនៅដ្ឋានពីដីដែលជាកម្មវត្ថុនៃការអភិវឌ្ឍន៍។

លោកស្រី អាណែត ឌិកសុន (Annette Dixon) នាយិកាធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា បានឱ្យដឹងថា ការអនុវត្តផ្នែកដីធ្លី និងការរុះរើលំនៅដ្ឋាន បន្តធ្វើឱ្យកម្ពុជាជួបប្រទះនូវបញ្ហាប្រឈមផ្នែកអភិវឌ្ឍន៍ដ៏តានតឹងបំផុតមួយចំនួននៅក្នុងប្រទេស។

លោកស្រីបានលើកឡើងថា "យើងត្រៀមខ្លួន ដើម្បីផ្តល់ការគាំទ្រដែលចាំបាច់សម្រាប់រដ្ឋាភិបាលកម្ពុជា ដើម្បីធានាថា ប្រជាពលរដ្ឋដែលត្រូវបានរុះរើលំនៅដ្ឋាន ឬដែលប្រឈមមុខនឹងការរុះរើលំនៅដ្ឋាន អាចទទួលបាននូវប្រព័ន្ធដោះស្រាយទំនាស់ សំណង និងមធ្យោបាយកសាងជីវភាពរស់នៅឡើងវិញប្រកបដោយយុត្តិធម៌ និងមានតម្លាភាព"។

សេចក្តីថ្លែងការណ៍របស់លោកស្រីឌិកសុន ត្រូវបានធ្វើឡើងស្របពេលនៃការចេញផ្សាយតាមវិបសាយនូវការឆ្លើយតបរបស់គណៈគ្រប់គ្រងធនាគារពិភពលោក ទៅនឹង "សំណើសុំការធ្វើអធិការកិច្ច" ដែលបានធ្វើឡើងនាពេលថ្មីៗនេះ ដើម្បីត្រួត ពិនិត្យលើកម្មវិធីគ្រប់គ្រង និងរដ្ឋបាលដីធ្លី (LMAP) នៅកម្ពុជា។ សំណើនេះត្រូវបានដាក់ជូនក្រុមអធិការកិច្ច (IP) — ជាអង្គភាពឯករាជ្យមួយរបស់ធនាគារពិភពលោក ដែលអាចស៊ើបអង្កេតលើការអះអាងថា តើធនាគារពិភពលោកបានគោរពតាមគោលនយោបាយ និងនីតិវិធីរបស់ខ្លួន ក្នុងកិច្ចដំណើរការប្រតិបត្តិការរបស់ខ្លួនដែរឬទេ។

សំណើមួយទាក់ទងនឹងកម្មវិធីគ្រប់គ្រង និងរដ្ឋបាលដីធ្លី ត្រូវបានដាក់ជូនក្រុមអធិការកិច្ចកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៩ ហើយគណៈគ្រប់គ្រងធនាគារពិភពលោកបានផ្តល់ចម្លើយតបរបស់ខ្លួន ទៅនឹងសំណើរនេះកាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៩។

ក្នុងចំណោមបញ្ហាដែលបានលើកឡើងនៅក្នុងសំណើនោះរួមមាន តើកម្មវិធីគ្រប់គ្រង និងរដ្ឋបាលដីធ្លី—ជាកម្មវិធីរយៈពេលប្រាំពីរឆ្នាំធ្វើសកម្មភាព ដើម្បីជួយគាំទ្រចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើទំនើបកម្មប្រព័ន្ធរដ្ឋបាលដីធ្លី—បានគោរពតាមគោលនយោបាយ និងនីតិវិធីទាក់ទិននឹងការរុះរើលំនៅដ្ឋាដោយមិនស្ម័គ្រចិត្ត និងការអភិបាលគម្រោងដែរឬទេ? ប្រការនេះទាក់ទងជាពិសេសទៅនឹងការរុះរើលំនៅដ្ឋាននៅក្នុងរាជធានីភ្នំពេញ កន្លែងដែលមិនមានកម្មសិទ្ធិដីធ្លី និងមានការរុះរើលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត បានកើនឡើងច្រើនជាច្រើនឆ្នាំមកហើយ។

ចម្លើយតបរបស់គណៈគ្រប់គ្រងធនាគារពិភពលោកលើកឡើងពីលទ្ធផលសម្រេចបាន និងចំណុចខ្វះខាតរបស់កម្មវិធីគ្រប់គ្រង និងរដ្ឋបាលដីធ្លី។ ជាពិសេស កម្មវិធីគ្រប់គ្រង និងរដ្ឋបាលដីធ្លី ៖

- បានជួយដល់ការចុះបញ្ជី និងការចេញប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លីបានចំនួន១.១ លានក្បាលដីនៅទូទាំងប្រទេស
- បានជួយរៀបចំផ្នែកសំខាន់ៗនៃក្របខ័ណ្ឌគោលនយោបាយ និងបទបញ្ជាជុំវិញបញ្ហាដីធ្លី

ប៉ុន្តែ នៅក្នុងបរិស្ថានអភិបាលកិច្ចដីធ្លីដ៏ស្មុគ្រស្មាញ ជាមួយនឹងតម្លៃដីបានកើនឡើងយ៉ាងលឿន នាំឱ្យមានការបណ្តេញចេញ និងការរុះរើលំនៅដ្ឋានជាច្រើនកើតឡើង ហើយស្ថានភាពនៃវិស័យដីធ្លីមានការប្រែប្រួលយ៉ាងខ្លាំង ក្នុងអំឡុងពេលនៃការអនុវត្តគម្រោងនេះ ហើយគម្រោងមិនអាចដើរទាន់ការផ្លាស់ប្តូរនេះ។

បន្ទាប់ពីរាជរដ្ឋាភិបាលបានសម្រេចចិត្តលុបចោលកម្មវិធីគ្រប់គ្រង និងរដ្ឋបាលដីធ្លីកាលពីខែកញ្ញាកន្លងទៅ ធនាគារពិភពលោកបានពិភាក្សាលើសកម្មភាពមួយចំនួនដែលអាចអនុវត្តបានជាមួយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីដោះស្រាយការប្រឈមនានាដែលកំពុងកើតមានឡើងជុំវិញបញ្ហាដីធ្លី និងការរុះរើលំនៅដ្ឋាន។

លោកស្រី ឌិកសុន មានប្រសាសន៍ថា ធនាគារពិភពលោកនឹងផ្តល់ជូនសម្រាប់ការពិនិត្យមើលក្របខ័ណ្ឌគោលនយោបាយ និងច្បាប់សម្រាប់ការផ្លាស់ប្តូរលំនៅដ្ឋានរបស់រដ្ឋាភិបាល និងផ្តល់ការគាំទ្របច្ចេកទេស និងថវិកាដើម្បីលើកកំពស់លក្ខខណ្ឌរស់នៅរបស់អ្នកតាំងទីលំនៅមិនផ្លូវការ និងសហគមន៍ដែលត្រូវបានរុះរើទៅនៅទីតាំងថ្មី។

លោកស្រីឌិកសុន បានមានប្រសាសន៍ថា "ប្រជាពលរដ្ឋដែលគ្មានដី ឬគ្មានប័ណ្ណកម្មសិទ្ធិសំគាល់អចលនទ្រព្យដែលមានសុវត្ថិភាពភាគច្រើនគឺជាជនក្រីក្រ និងទំនងជានៅតែក្រីក្រដដែល"។ លោកស្រីបន្តថា "ការកាន់កាប់ដីធ្លីដែលមានសុវត្ថិភាព គឺជាកត្តារួមចំណែកដ៏សំខាន់ ដែលអាចជួយឱ្យប្រជាពលរដ្ឋចាកចេញពីភាពក្រីក្របាន។ ដូច្នេះហើយបានជាធនាគារពិភពលោកចូលរួម និងនៅបន្តចូលរួមក្នុងវិស័យដីធ្លីនេះនៅកម្ពុជា"។